# សិក្ខាសាលាបណ្តុះបណ្តាលស្តីពី ប.វ.ស

បណ្តាញថ្នាំពុលអាស៊ីប៉ាស៊ីហ្វិក សហការជាមួយអង្គការសេដាក រៀបចំវគ្គបណ្តុះបណ្តាលមួយស្តីអំពី ប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវតាមគោលការណ៍ធម្មជាតិ (ប.វ.ស) រយៈពេល ៥ ថ្ងៃ ចាប់ផ្តើមពីថ្ងៃទី ០៨ ដល់ ១២ ខែកញ្ញា ឆ្នាំ ២០០៨ នៅសណ្ឋាគារហ្គោលឌីយ៉ាណា ក្រុងភ្នំពេញ ។ សិក្ខាកាមដែលជាកសិករ និងតំណាងអង្គការក្រៅរដ្ឋាភិបាល ចំនួន ១៣ នាក់ (ស្ត្រី ៣ នាក់) មកពីបណ្តាប្រទេសអាស៊ីចំនួន ៥ រួមមាន ប្រទេសម៉ាឡេស៊ី ឥណ្ឌូនេស៊ី ថៃ ចិន និង ប៉ាគីស្ថាន ចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលនេះ។ គោលបំណងសំខាន់របស់វគ្គបណ្តុះបណ្តាលនេះរួមមាន ដើម្បីៈ




- ពិភាក្សាអំពីគោលការណ៍ និងការអនុវត្តប.វ.ស
- ចែករំលែកនូវយុទ្ធសាស្ត្រ និងវិធីសាស្ត្ររបស់ សេដាក ក្នុងការអភិវឌ្ឍន៍ និងផ្សព្វផ្សាយ ប.វ.ស នៅក្នុងប្រទេសកម្ពុជា
- ចែករំលែកបទពិសោធន៍របស់កសិករក្នុងការប្រើប្រាស់គំនិត ប.វ.ស ដើម្បីបង្កើនការធ្វើស្រែ
- ចែករំលែកបទពិសោធន៍របស់កសិករក្នុងការអភិវឌ្ឍន៍ ប្រព័ន្ធប្រពលវប្បកម្ម និងការធ្វើឱ្យប្លែកពីគ្នានៃផលិតកម្មស្រូវនៅក្នុងស្រែ

នៅក្នុងកំឡុងពេល ៥ ថ្ងៃនៃការបណ្តុះបណ្តាលនេះ សិក្ខាកាមបានធ្វើការសិក្សា និងពិភាក្សា ចែករំលែកបទពិសោធន៍គ្នាយ៉ាងសស្រាក់សស្រាំ ពិសេសទាក់ទងទៅនឹង ប.វ.ស ថែមទាំងបានចុះទៅទស្សនៈកិច្ចសិក្សាជួបសំភាសន៍កសិករដោយផ្ទាល់នៅនៅក្នុងខេត្តចំនួន ៣ គឺ ខេត្តកណ្តាល កំពង់ឆ្នាំង និងខេត្តតាកែវ។ បណ្ឌិត **យ៉ង សាំងកុមារ** ប្រធានអង្គការសេដាក និងលោក **ឌី ធី** ដែលជាអ្នកបណ្តុះបណ្តាលបានចូលរួមយ៉ាង សកម្មក្នុងការចូលរួមចែករំលែកបទពិសោធន៍ និងចំណេះដឹងស្តីពី ប.វ.ស ការពន្យល់ចែកឯកសារលំហាត់អនុវត្ត ការពិភាក្សាក្រុម និងការបញ្ចាំងខ្សែវីដេអូខ្លី ប.វ.ស ជូលដល់សិក្ខកាម ។ ជាលទ្ធផល តាមរយៈវគ្គបណ្តុះបណ្តាលនេះ សិក្ខាកាមទទួលបានចំណេះដឹងជាច្រើនទាក់ទងនឹងគោលការណ៍ និងការអនុវត្ត ប.វ.ស នៅក្នុងប្រទេសកម្ពុជា ពិសេសយុទ្ធសាស្ត្រសេដាកក្នុងការផ្សារភ្ជាប់កសិករទៅនឹងទីផ្សារ និងការរៀបចំជាទស្សនៈកិច្ចជូលដល់កសិករ និងអចិជនជាដើមដោយប្តេជ្ញាយកទៅអនុវត្តនៅក្នុងប្រទេសរបស់ខ្លួនពេលខ្លួនត្រលប់ទៅវិញ។